ភ្នំពេញ , ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ១៩៩៣

# សេចក្តីសំរេចលេខ ១៤ សសរ ស្តីពីការបង្កើតគណៈកម្មការ វាយតំលៃអំណោយរបស់ក្រុម អ៊ិនតាក់ ជប៉ុន ប្រចាំការនៅខេត្តតាកែវ

****

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- បានឃើញក្រឹត្យ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ របស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះមុខរដ្ឋនៃកម្ពុជា ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃ កម្ពុជា
- យោងសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការវាយតំលៃអំណោយរបស់ក្រុម អ៊ិនតាក់ ជប៉ុនប្រចាំនៅខេត្តតាកែវរួម មានសមាសភាពដូច តទៅ ÷

| | |
|---|---|
| - តំណាង ក្រសួងហិរញ្ញវត្ថុ | ជាប្រធាន |
| - តំណាងក្រសួង ផែនការ | ជាអនុប្រធាន |
| - តំណាង ក្រសួងថាមពល និង រ៉ែ | ជាសមាជិក |
| - តំណាង ក្រសួងកិច្ចការនារី យុវជន និង កីឡា | ជាសមាជិក |
| - លោក ឌី សូភីន តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| - តំណាង រដ្ឋករទឹក រដ្ឋធានីភ្នំពេញ | ជាសមាជិក |
| - តំណាង ខេត្តតាកែវ | ជាសមាជិក |

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ច ចុះពិនិត្យ និង វាយតំលៃអំណោយទាំងអស់ដែលក្រុម អ៊ិនតាក់ ជប៉ុន ប្រចាំខេត្តតាកែវ បានផ្តល់ជូនរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា ។

- ធ្វើបញ្ជីសារពើភណ្ឌ តាមយថាប្រភេទ និង បរិមាណអោយបានច្បាស់លាស់ ហើយរាយការណ៍ជូនរដ្ឋាភិបាល ជាតិបណ្តោះនៃកម្ពុជា ។

**ប្រការ ៣ :** គណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និង ចុះបំពេញបេសកកម្ម

នៅក្នុងសប្តាហ៍ទី ១ នៃ ខែ សីហា ឆ្នាំ ១៩៩៣ នេះ ។

**ប្រការ ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធានរដ្ឋាករទឹក និង អភិបាលខេត្តតាកែវ ត្រូវទទួលបន្ទុកអនុវត្ត សេចក្តីសម្រេចនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

ជ. រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

សហនាយករដ្ឋមន្ត្រី

ហត្ថលេខា ហត្ថលេខា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

ភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៣

លេខ ៣៤០១ អស គបឌ

រដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
សូមគោរពជូនសម្តេចក្រុមហ្លួង និង ជូនឯកឧត្តមសហប្រធាន
ក្រុមប្រឹក្សារដ្ឋមន្ត្រី

**កម្មវត្ថុ :** បញ្ហាស្នើសុំខ្ចោះបរិក្ខាររបស់អង្គភាពទ័ពជប៉ុនក្នុងអ៊ុនតាក់

**យោង :** លិខិតចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៩៣ របស់សហប្រធានរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា ផ្ញើជូននាយករដ្ឋមន្ត្រីជប៉ុន ។

ទូលបង្គំ ខ្ញុំមានកិត្តិយសសូមទូលថ្វាយព្រះអង្គស្តេចក្រុមហ្លួង និង ឯកឧត្តមសហប្រធានជា